ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ( គ.ជ.ប )

# សៀវភៅណែនាំ

# ស្តីពី

# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ក្នុងដំណាក់កាលនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**(គ.ជ.ប)**

# សៀវភៅណែនាំ

**ស្តីពី**

# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ក្នុងដំណាក់កាលនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧

# មាតិកា


**ទំព័រ**

**អក្សរកាត់** ------------------------------------------------ i

**គោលបំណង** ------------------------------------------------ ii

**ជំពូកទី ១ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង** ------ ១

**ផ្នែកទី ១ ការប្តឹងតវ៉ា ឬការប្តឹងជំទាស់** ------------------------ ១

១. ពាក្យបណ្តឹង------------------------------------------------១

២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ----------------------------------------២

**ផ្នែកទី ២ លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត**-------------------------------៣

**ផ្នែកទី ៣ បណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត**------------------- ៥

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស-----៥

១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស -----------------៥

១.២ ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស------------------------ ៧

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប --------៨

២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប---------------------៨

២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ------------------------- ១០

៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាជម្មនុញ្ញ -- ១០

៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាជម្មនុញ្ញ----- ១០

៣.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាជម្មនុញ្ញ------------ ១១

**ផ្នែកទី ៤ បណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង**-------------------- ១២

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ------ ១៣

១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស ------- ១៣

១.២ ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស---------------- ១៥

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ----- ១៧

២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប----------------- ១៧

២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ------------------------------- ១៨
៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ - ២០
៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ----- ២០
៣.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ------------- ២០
**ផ្នែកទី៥ ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ នៅពេល ក.ច.ប ត្រូវបានរំសាយ** ------ ២៣
**ផ្នែកទី ៦ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត** ------------------------------ ២៥
I. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ----------------------------------------------------------------- ២៥
១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស--- ២៥
១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស ------- ២៥
១.២ ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស--------------- ២៧
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ----- ៣០
២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប ----------- ៣០
២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប------------------- ៣១
៣.ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ -------------------------------------------------------- ៣៣
៣.១ ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ---- ៣៣
៣.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---- ៣៣
II. បណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត------------------------ ៣៥
**ផ្នែកទី ៧ នីតិវិធីអនុវត្តសេចក្តីសម្រេចស្ថាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់**---------------------------------------------- ៣៧
**ជំពូកទី ២ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង** ------------------------------------------ ៣៨

**ផ្នែកទី ១ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ** ------------------- ៣៨

១. សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ------------------------------------------ ៣៨

១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស --- ៣៨

១.២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ------------------------------------ ៣៩

២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬ ក្រុមប្រឹក្សាជំនុំជម្រះ ------------------------------------------------ ៣៩

២.១ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច នៃ កបឃ.ស------------------------------------------------------------ ៣៩

២.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប --------------- ៤០

**ផ្នែកទី ២ សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី**------------------------------------------- ៤១

១. សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ------------------------------------------ ៤១

២. សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្ដឹង------------------------------------ ៤២

៣. សិទ្ធិ និងកាតព្វកិច្ចរបស់ចុងចម្លើយ------------------------------------- ៤២

៤. សិទ្ធិ និងកាតព្វកិច្ចរបស់មេធាវី ឬតំណាង ---------------------------- ៤៣

៥. សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ------------------------------------------ ៤៣

**ផ្នែកទី ៣ នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ**-------------- ៤៤

១. ប្រភេទសវនាការ---------------------------------------------------------- ៤៤

២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ------- ៤៥

៣. ពេលវេលាដោះស្រាយពាក្យបណ្ដឹង ------------------------------------- ៤៥

៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើក សវនាការ --------------------------------------------------------------- ៤៥

៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេចនៅ កបឃ.ស -------------------------------------------------------------- ៤៥

៤.២ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប------------------------------------- ៤៥
៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ------------------------------------------------ ៤៦
៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ------------------------ ៤៧
៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ------ ៤៩
៨. មធ្យោបាយបង្ហាញភស្តុតាង ------------------------------------------------ ៥០
៩. ការប្រើប្រាស់ និងបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) --------- ៥០
១០. ទម្រង់ផ្សេងៗសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ ---------------------------------------------------------------- ៥២
**ឧបសម្ព័ន្ធ**----------------------------------------------------------------------- ៥៣
**ឧបសម្ព័ន្ធទី ១ ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)** ------------------- ៥៣
**ឧបសម្ព័ន្ធទី ២ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)**------- ៥៤
**ឧបសម្ព័ន្ធទី ៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង**------------ ៥៥
**ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារសម្បថ**------------------------------- ៥៦
**ឧបសម្ព័ន្ធទី ៥ សម្រង់មាត្រាពាក់ព័ន្ធនឹងទោសប្បញ្ញត្តិ ក្នុងពេលចុះឈ្មោះបោះឆ្នោត ដែលមានចែងក្នុងជំពូកទី១០ នៃ ច.ប.ត.រ**--- ៥៧

# អក្សរកាត់

| | |
|---|---|
| ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| បទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ | ប.ន.ប.ច |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត | ន.គ.ទ.ប |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |
| ក្រុមចុះឈ្មោះបោះឆ្នោតពិសេស | ក.ច.ប.ព |
| អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត | ឯ.អ |
| ទម្រង់បែបបទលេខ | ទ. |
| ទម្រង់បែបបទសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត | ទ.១០០៩ |
| ទម្រង់បែបបទពាក្យបណ្តឹង | ទ.១២០២ |
| ទម្រង់បែបបទសម្រង់សេចក្តីសម្រេច | ទ.១២០៣ |

# គោលបំណង

សៀវភៅណែនាំស្តីពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត **ឆ្នាំ២០១៧** ត្រូវបានរៀបចំឡើងដោយផ្អែកលើ ច.គ.ជ.ប ច.ប.ត.រ និង ប.ន.ប.ច ។ សៀវភៅណែនាំនេះរៀបចំឡើងដើម្បីជាជំនួយស្មារតីសម្រាប់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ឱ្យបានយល់ដឹងអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧។ សៀវភៅណែនាំនេះចែកចេញជាពីរជំពូក ៖

**ជំពូកទី ១** បង្ហាញដោយសង្ខេបអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅគ្រប់ដំណាក់កាល នៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ។

**ជំពូកទី ២** បង្ហាញដោយសង្ខេបអំពីនីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ដែលកើតមានឡើងនៅគ្រប់ដំណាក់កាល ក្នុងនោះមានជាអាទិ៍ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ក្រុមប្រឹក្សាជំនុំជម្រះ ប្រភេទសវនាការ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង។

ផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះមាន ៥ ឧបសម្ព័ន្ធ៖

- ឧបសម្ព័ន្ធទី ១ ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)
- ឧបសម្ព័ន្ធទី ២ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)
- ឧបសម្ព័ន្ធទី ៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង
- ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារនៃសម្បថ
- ឧបសម្ព័ន្ធទី ៥ សម្រង់មាត្រាពាក់ព័ន្ធនឹងទោសប្បញ្ញត្តិ ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត ដែលមានចែងក្នុងជំពូកទី១០ នៃ ច.ប.ត.រ ។

## ជំពូកទី ១
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
### ផ្នែកទី ១
### ការប្តឹងតវ៉ា ឬការប្តឹងជំទាស់

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានភាពមិនត្រឹមត្រូវ ដូចមានចែងក្នុង ច.ប.ត.រ ឬ/និង ប.ន.ប.ច ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

### ១. ពាក្យបណ្តឹង

ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្តឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្តឹងជំទាស់**) ។ ទ.១២០២ នេះត្រូវបានប្រគល់ជូនអ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ។

អ្នកប្តឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជូសខ្លួនបាន។

ពាក្យបណ្តឹង ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។
២- កម្មវត្ថុនៃបណ្តឹង។
៣- ប្រភេទនៃអំពើល្មើស។
៤- ពេលវេលា និងទីកន្លែងនៃការសុំចុះឈ្មោះបោះឆ្នោត ឬបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ឬការប្រព្រឹត្តអំពើល្មើស។
៥- បើអាចធ្វើបានបញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលបានរំលោភ។
៦- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់។
៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន។
៨- ភស្តុតាងផ្សេងៗទៀត បើមាន។

ពាក្យបណ្តឹងអនាមិក ពុំត្រូវបានចាត់ទុកជាបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

ពាក្យបណ្តឹងប្តឹងពីអញ្ញាតជន[១] ត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ កបឃ.ស ឬ គ.ជ.ប ត្រូវជូនដំណឹងទៅអ្នកប្តឹងវិញអំពីករណីនេះក្នុងរយៈពេលសមស្រប។

## ២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្តឹងតវ៉ា ឬ បណ្តឹងជំទាស់

ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យផ្លូវការទេ។

[១] ជនមិនស្គាល់អត្តសញ្ញាណ

# ផ្នែកទី ២

## លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត

ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត ត្រូវបានកំណត់ក្នុងមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ មាត្រា ៤៦ និងមាត្រា ៥១ នៃ ច.ប.ត.រ ។

ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- **ក.** ត្រូវបង្ហាញខ្លួន និងមាន អ.ខ នៅចំពោះមុខ ក.ច.ប ដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ។ អ.ខ ដែលមានសុពលភាពស្របតាមអនុក្រឹត្យលេខ ១៩៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ អាចយកទៅប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោតបាន។
- **ខ.** មានសញ្ជាតិខ្មែរ។
- **គ.** មានអាយុដប់ប្រាំបី (១៨) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត (កើតមុន ឬត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០០) ។
- **ឃ.** មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។
- **ង.** មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

**កំណត់សម្គាល់៖**

-ប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់។ ផ្អែកតាមមាត្រា ១៤៤ នៃ ច.ប.ត.រ ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយ គ.ជ.ប ។

-ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់បុគ្គលនោះ ដើម្បីចុះឈ្មោះបោះឆ្នោត ។

-លំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។ ក្នុងករណីដែលកន្លែងជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកជាលំនៅឋាន។ ទីសំណាក់សំដៅលើទីស្ថានដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែងក្នុងរយៈពេលជាកំណត់ណាមួយ។

# ផ្នែកទី ៣

## បណ្ដឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត

អ្នកសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបាន ក.ច.ប បដិសេធការសុំចុះឈ្មោះបោះឆ្នោត ឬតំណាង មានសិទ្ធិប្ដឹងតវ៉ាទៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ។

### ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស

#### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ កបឃ.ស

ក. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២។ ក្នុងករណីដែលអ្នកប្ដឹងមកប្ដឹងតវ៉ាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពី ទ.១២០២ កបឃ.ស ត្រូវណែនាំអ្នកប្ដឹងឱ្យបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង

២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១០០៩ ។

គ. បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងសួរកត់ត្រាក្នុងកំណត់ហេតុ ហើយឃើញថា៖

ឃ.១ កម្មវត្ថុនៃបណ្ដឹង មិនទាក់ទងនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬ សមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹង

គ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ កបឃ.ស ទេ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**"។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

**ឃ.២** ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១០០៩ មេឃុំ ចៅសង្កាត់ ឬជំទប់ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយអំឡុងពេលកំណត់ ដូចមានចែងក្នុងមាត្រា ៥៤ នៃ ច.ប.ត.រ ដែលជាហេតុធ្លស់សិទ្ធិ[២] ក្នុងការប្ដឹងមក កបឃ.ស ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**"។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.៣** ពាក្យបណ្ដឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់

---

២ ការបាត់បង់សិទ្ធិ ដោយហេតុមិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវឱ្យបំពេញក្នុងរយៈពេលមានកំណត់

ថា "**ពាក្យបណ្តឹងមិនមានបញ្ជាក់អត្តសញ្ញាណអ្នកប្តឹង ឬមិន មានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...**" ។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.៤** កម្មវត្ថុនៃបណ្តឹងទាក់ទងនឹងការសុំចុះឈ្មោះបោះឆ្នោត និងពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១០០៩ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់**) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់លើពាក្យបណ្តឹងគ្រប់ច្បាប់ ហើយបំពេញកាលបរិច្ឆេទ ពេលវេលា (**មិនឱ្យហួសរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង**) និងទីកន្លែងដែលនឹងត្រូវបើកការប្រជុំសម្រេច រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងការប្រជុំសម្រេច ១ (មួយ) ច្បាប់។

## ១.២ ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស

**ក.** ក្នុងករណីដែលពាក្យបណ្តឹងទាក់ទងនឹងការសុំចុះឈ្មោះបោះឆ្នោត និងពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលនៅជាធរមាន និងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ទាំងមូល ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាប្រជុំសម្រេចមានឧត្តមានុភាព។

ខ. កបឃ.ស ត្រូវបើកការប្រជុំសម្រេចជាសាធារណៈសម្រេចបដិសេធ ឬយល់ព្រមលើបណ្តឹងតវ៉ា ដោយធ្វើកំណត់ហេតុប្រជុំសម្រេច។ យោង កំណត់ហេតុប្រជុំសម្រេច កបឃ.ស ត្រូវចាត់លេខាធិការអង្គប្រជុំ សម្រេច ឱ្យស្រង់សេចក្តីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៣ (បី) ច្បាប់។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំ សម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គ. បន្ទាប់ពី កបឃ.ស បើកការប្រជុំសម្រេចលើបណ្តឹងតវ៉ា ក្នុងករណី ដែល៖

- **បដិសេធលើបណ្តឹង ៖** កបឃ.ស ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹង តវ៉ាទៅនឹងសេចក្តីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្តឹង ៖** កបឃ.ស ចាត់ ក.ច.ប ឱ្យអនុវត្តការ ចុះឈ្មោះតាមលក្ខខណ្ឌដូចមានចែងក្នុង**មាត្រា ៥១ ចំណុច ឃ នៃ ច.ប.ត.រ** ។

ឃ. សមាសភាពក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវអនុវត្តតាម លក្ខខណ្ឌដូចក្នុងជំពូកទី ២ ផ្នែកទី ១ នៃសៀវភៅណែនាំនេះ (**ទំព័រ ៣៨**) ។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

ក. អ្នកប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ ពីថ្ងៃបានទទួល ទ.១២០៣ ។ អ្នកប្តឹងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

ខ. មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវពិនិត្យឱ្យប្រាកដថា ព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុង**ចំណុច ១ (ទំព័រ ១)** ត្រូវបាន បំពេញក្នុងពាក្យបណ្តឹង និងគោរពអំឡុងពេលកំណត់។

គ. ក្នុងករណីដែលពាក្យបណ្ដឹងពុំបានធ្វើឡើងក្នុងអំឡុងពេលកំណត់ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ កបឃ.ស ឬពាក្យបណ្ដឹងមិនពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប ចារបដិសេធ ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្ដឹងនោះ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ. ពាក្យបណ្ដឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធ ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្ដឹងនោះ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ង. មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃលើកំណត់ហេតុ មន្ត្រីដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ។

ច. ចំពោះពាក្យបណ្ដឹងមានព័ត៌មានគ្រប់គ្រាន់ និងដាក់ក្នុងអំឡុងពេលកំណត់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវទទួលពាក្យបណ្ដឹង រួចជម្រាបអ្នកប្ដឹងថាកាលបរិច្ឆេទ និងទីកន្លែងនៃការបើកសវនាការនឹងជម្រាបជូននៅពេលក្រោយយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកសវនាការ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្ដីការ គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់។

### ២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចលើបណ្ដឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

ខ. គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើបណ្ដឹងតវ៉ា ដោយចេញ ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន កបឃ.ស ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គ. បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើបណ្ដឹងតវ៉ា ក្នុងករណីដែល៖

- **បដិសេធលើបណ្ដឹង៖** គ.ជ.ប ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្ដឹង៖** គ.ជ.ប ចាត់គណៈលេខាធិការសវនាការ ឱ្យផ្ញើ ទ.១២០៣ ទៅ កបឃ.ស ដើម្បីចាត់ ក.ច.ប ឬ ក.ច.ប.ព ចុះឈ្មោះអ្នកប្ដឹងតវ៉ានោះ ដោយអនុវត្តតាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងមាត្រា **៥១** ចំណុច **ឃ** នៃ ច.ប.ត.រ ។

ឃ. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី ២ ផ្នែកទី ១ នៃសៀវភៅណែនាំ នេះ (ទំព័រ **៣៩**)។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ៣.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

ខ. នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ា ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

ខ. នីតិវិធីដោះស្រាយពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

គ. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត



# ផ្នែកទី ៤
# បណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

ជនណាក៏ដោយមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរ តាម ទ.១២០២ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងទៅ កបឃ.ស ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

**ពាក្យបណ្ដឹងតវ៉ា** អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ ឬត្រូវបាន គ.ជ.ប លុបឈ្មោះមិនត្រឹមត្រូវ ទៅតាមករណីដូចខាងក្រោម៖

- សាមីអ្នកប្ដឹងតវ៉ា បានទៅសុំចុះឈ្មោះបោះឆ្នោតពិតប្រាកដជាមួយនឹង ក.ច.ប ហើយត្រូវបានទទួលចុះឈ្មោះ ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូង នៃការិយាល័យបោះឆ្នោតដែលខ្លួនបានចុះឈ្មោះ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យផ្សេង ឬមានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែបែរជាមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង។
- សាមីអ្នកប្ដឹងតវ៉ាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូងមានភាពមិនច្បាស់លាស់ ឬមិនត្រឹមត្រូវតាមព័ត៌មានដែលគាត់បានផ្ដល់ឱ្យ ។
- សាមីអ្នកប្ដឹងតវ៉ា ឃើញឈ្មោះដែរ តែឈ្មោះនោះស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់។

**ពាក្យបណ្ដឹងជំទាស់** អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង៖

- ក្នុងករណីដែលជននោះមិនមានលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដោយសារ៖
    - មិនមានសញ្ជាតិខ្មែរ
    - មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោត ស្របតាមការកំណត់នៃ ច.ប.គ.រ
    - មិនមានទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត
    - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

- ក្នុងករណីដែលជននោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គបឃ.ស

### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គបឃ.ស

ក. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ។ ក្នុងករណីដែលអ្នកប្ដឹងមកប្ដឹងតវ៉ា ឬប្ដឹងជំទាស់ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពី ទ.១២០២ គបឃ.ស ត្រូវណែនាំអ្នកប្ដឹងឱ្យបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្ដឹងតវ៉ា**) និង ៤ (បួន) ច្បាប់ (**ករណីប្ដឹងជំទាស់**)។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង គបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

គ. បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងសួរកត់ត្រាក្នុងកំណត់ហេតុហើយឃើញថា៖

ឃ.១ កម្មវត្ថុនៃបណ្ដឹងមិនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ គបឃ.ស ទេ។ ដូចនេះ គបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**"។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូន

អ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ឃ.២ ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់ ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងនេះបានដាក់ក្រោយអំឡុងពេលកំណត់ ដូចមានចែងក្នុងកថាខណ្ឌចុងក្រោយមាត្រា ៦១ នៃ ច.ប.ត.រ ដែលជាហេតុផ្តល់សិទ្ធិក្នុងការប្តឹងមក កបឃ.ស ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**"។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ.៣ ពាក្យបណ្តឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬជំទប់ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសអំឡុងពេលកំណត់ នៃការដាក់ពាក្យបណ្តឹងហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងមិនមានបញ្ជាក់អត្តសញ្ញាណអ្នកប្តឹង ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...**"។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់

ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ឧប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.៤** កម្មវត្ថុនៃបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់ ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់**) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់លើពាក្យបណ្ដឹងគ្រប់ច្បាប់ ហើយបំពេញកាលបរិច្ឆេទ ពេលវេលា (**មិនឱ្យហួសរយៈពេល ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង**) និងទីកន្លែងដែលនឹងត្រូវបើកការប្រជុំសម្រេច រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹងជំទាស់ ១ (មួយ) ច្បាប់ (**ករណីប្ដឹងជំទាស់**) ទុកបិទផ្សាយនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់។

## ១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គបឃ.ស

**ក.** ក្នុងករណីដែលពាក្យបណ្ដឹងទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់ គបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិក គបឃ.ស ទាំងមូល ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

**ខ.** គបឃ.ស ត្រូវបើកការប្រជុំសម្រេចជាសាធារណៈសម្រេចបដិសេធ ឬយល់ព្រមលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ដោយធ្វើកំណត់ហេតុប្រជុំសម្រេច។ យោងកំណត់ហេតុប្រជុំសម្រេច គបឃ.ស ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេចឱ្យស្រង់សេចក្ដីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៣ (បី) ច្បាប់ (**ករណីប្ដឹងតវ៉ា**) ឬ ៤ (បួន) ច្បាប់ (**ករណីប្ដឹង**

**ជំទាស់**)។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** ក្នុងការប្រជុំសម្រេចលើបណ្ដឹងតវ៉ា ដែលទាក់ទងនឹងការកែតម្រូវទិន្នន័យ ឬរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត កបឃ.ស ត្រូវយកចិត្តទុកដាក់លើចំណុចដូចខាងក្រោម៖

**គ.១** ការកែតម្រូវទិន្នន័យ ត្រូវផ្អែកលើឯកសារសំអាងដូចជា អ.ខ ឬ ឯ.អ ដែលបានប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ហើយការីកុំព្យូទ័របានថតបញ្ជូនតាមប្រព័ន្ធកុំព្យូទ័រមក គ.ជ.ប ។

**គ.២** ការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត (ករណីឈ្មោះស្ទួន) ត្រូវផ្អែកលើឈ្មោះ និងទិន្នន័យដែលបានចុះឈ្មោះចុងក្រោយ ឬតាមការស្នើសុំរបស់សាមីខ្លួន ដោយផ្អែកលើឯកសារសំអាងច្បាស់លាស់។

**ឃ.** កបឃ.ស អាចទាក់ទងមក ន.គ.ទ.ប តាមរយៈ លធ.ខប ដើម្បីធ្វើការបញ្ជាក់បន្ថែមលើទិន្នន័យអ្នកសុំកែតម្រូវ មុននឹងធ្វើការសម្រេចលើពាក្យបណ្ដឹងតវ៉ា។

**ង.** បន្ទាប់ពី កបឃ.ស បើកការប្រជុំសម្រេចលើបណ្ដឹងតវ៉ា ក្នុងករណីដែល៖

- **បដិសេធលើបណ្ដឹង ៖** កបឃ.ស ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។
- **យល់ព្រមលើបណ្ដឹង ៖** កបឃ.ស ធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយ ទ.១២០៣ ដើម្បីសុំបញ្ចូលឈ្មោះ ឬរក្សាទុកឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ។

**ច.** បន្ទាប់ពី កបឃ.ស បើកការប្រជុំសម្រេចលើបណ្ដឹងជំទាស់ ក្នុងករណីដែល៖

- **បដិសេធលើបណ្ដឹង ៖** កបឃ.ស ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្ដឹង ៖** កបឃ.ស ជូនដំណឹងទៅអ្នកដែលត្រូវគេប្ដឹងជំទាស់ថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ព្រមទាំងធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយ ទ.១២០៣ ។

ឆ. សមាសភាពក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី ២ ផ្នែកទី ១ នៃសៀវភៅណែនាំនេះ (**ទំព័រ ៣៨**) ។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

ក. អ្នកប្ដឹងតវ៉ា អ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។ អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្ដឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្ដឹងជំទាស់**)។

ខ. មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវពិនិត្យឱ្យប្រាកដថា ព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុង**ចំណុច ១** (**ទំព័រ ១**) ត្រូវបានបំពេញក្នុងពាក្យបណ្ដឹង និងគោរពអំឡុងពេលកំណត់។

គ. ក្នុងករណីដែលពាក្យបណ្ដឹងពុំបានធ្វើឡើងក្នុងអំឡុងពេលកំណត់ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ កបឃ.ស ឬពាក្យបណ្ដឹងមិនពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប ចារបដិសេធ ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្ដឹងនោះ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ. ពាក្យបណ្តឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធ ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹងនោះ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ង. មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

ច. ចំពោះពាក្យបណ្តឹងមានព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ និងដាក់ក្នុងអំឡុងពេលកំណត់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវទទួលពាក្យបណ្តឹង រួចជម្រាបអ្នកប្តឹងថាកាលបរិច្ឆេទ និងទីកន្លែងនៃការបើកសវនាការនឹងជម្រាបជូននៅពេលក្រោយយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (**ករណីប្តឹងជំទាស់**) បិទផ្សាយនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់ និងទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

ក. គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

**ខ.** ក្នុងករណីដែល គ.ជ.ប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្ដឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅដើមបណ្ដឹង ហើយប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** ក្នុងករណីដែល គ.ជ.ប បើកសវនាការសង្ខេប ឬជាសាធារណៈ សម្រេចយល់ព្រម ឬបដិសេធលើបណ្ដឹងដោយចេញ ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ (**ករណីប្ដឹងតវ៉ា**) ឬចំនួន ៥ (ប្រាំ) ច្បាប់ (**ករណីប្ដឹងជំទាស់**)។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (**ករណីប្ដឹងជំទាស់**) ផ្ញើជូន កបឃ.ស ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើបណ្ដឹងតវ៉ា ក្នុងករណីដែល៖

- **បដិសេធលើបណ្ដឹង ៖** គ.ជ.ប ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។
- **យល់ព្រមលើបណ្ដឹង៖** គ.ជ.ប ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោត ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ៧.៤.២.១ នៃ ប.ន.ប.ច ។

**ង.** បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើបណ្ដឹងជំទាស់ ក្នុងករណីដែល៖

- **បដិសេធលើបណ្ដឹង ៖** គ.ជ.ប ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។
- **យល់ព្រមលើបណ្ដឹង ៖** គ.ជ.ប ជម្រាបអ្នកត្រូវគេប្ដឹងជំទាស់ថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

ច. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី ២ ផ្នែកទី ១ នៃសៀវភៅណែនាំនេះ (**ទំព័រ ៣៩**)។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. អ្នកប្តឹង ឬអ្នកត្រូវគេប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។

ខ. នីតិវិធីនៃការដាក់ ការទទួលពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ៣.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

ខ. នីតិវិធីដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

គ. ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចយល់ព្រមលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

ឃ. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

### គំនូសបំព្រួញទី២

ក. ករណីពាក្យបណ្តឹងតវ៉ា



## គំនូសបំព្រួញទី៣

### ខ. ករណីពាក្យបណ្តឹងជំទាស់



## ផ្នែកទី ៥
## ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ នៅពេល ក.ច.ប ត្រូវបានរំសាយ

នៅពេល ក.ច.ប ត្រូវបានរំសាយ សេចក្តីសម្រេចស្ថាពររបស់ កបឃ.ស ឬសេចក្តីសម្រេចរបស់ គ.ជ.ប ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានអនុវត្តដូចខាងក្រោម៖

### ក. ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ កបឃ.ស

បន្ទាប់ពីបានទទួលរបាយការណ៍ ដែលមានភ្ជាប់មកជាមួយនូវ ទ.១២០៣ ដូចមានចែងក្នុងចំណុច ៧.៣.៩.២ និង ៧.៣.១០.២ នៃ ប.ន.ប.ច គ.ជ.ប ត្រូវ៖

- **ករណីយល់ព្រមលើបណ្តឹងតវ៉ា**
  - ចាត់ឱ្យ ក.ច.ប.ព ដូចចែងក្នុងប្រការ ២.១០ នៃ ប.ន.ប.ច ចុះទៅជួបសាមីអ្នកតវ៉ា ដើម្បីចុះឈ្មោះបោះឆ្នោត ដោយត្រូវអនុវត្តការចុះឈ្មោះដូចមានចែងក្នុងចំណុច ឃ មាត្រា ៥១ នៃ ច.ប.ត.រ និងចំណុច ៦.៥.២០ ៦.៥.២១ និង ៦.៥.២២ នៃ ប.ន.ប.ច (ករណីចុះឈ្មោះបោះឆ្នោត) ឬ
  - ចាត់ឱ្យ ន.គ.ទ.ប កែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ (ករណីកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ)។
- **ករណីយល់ព្រមលើបណ្តឹងជំទាស់**

ចាត់ឱ្យ ន.គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវបានគេប្តឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

### ខ. ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ គ.ជ.ប

បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប គ.ជ.ប ត្រូវ៖

- **ករណីយល់ព្រមលើបណ្តឹងតវ៉ា**
  - ចាត់ឱ្យ ក.ច.ប.ព ដូចចែងក្នុងប្រការ ២.១០ នៃ ប.ន.ប.ច ចុះទៅជួបសាមីអ្នកតវ៉ា ដើម្បីចុះឈ្មោះបោះឆ្នោត ដោយត្រូវអនុវត្តការចុះឈ្មោះដូចមានចែងក្នុងចំណុច ឃ មាត្រា ៥១ នៃ ច.ប.ត.រ និងចំណុច ៦.៥.២០ ៦.៥.២១ និង ៦.៥.២២ នៃ ប.ន.ប.ច (ករណីចុះឈ្មោះបោះឆ្នោត) ឬ

- ចាត់ឱ្យ ន.គ.ទ.ប កែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ (ករណីកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ) និងផ្ញើ ទ.១២០៣ ចំនួន ១ (មួយ) ច្បាប់ជូន កបឃ.ស ដើម្បីជាព័ត៌មាន និងទុកជាឯកសារ។

- **ករណីយល់ព្រមលើបណ្តឹងជំទាស់**

ចាត់ឱ្យ ន.គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវបានគេប្តឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

## គ. ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចចែងក្នុងចំណុច ៧.៣.២៨ នៃ ប.ន.ប.ច គ.ជ.ប ត្រូវ៖

- **ករណីយល់ព្រមលើបណ្តឹងតវ៉ា**

- ចាត់ឱ្យ ក.ច.ប.ព ដូចចែងក្នុងប្រការ ២.១០ នៃ ប.ន.ប.ច ចុះទៅជួបសាមីអ្នកតវ៉ា ដើម្បីចុះឈ្មោះបោះឆ្នោត ដោយត្រូវអនុវត្តការចុះឈ្មោះដូចមានចែងក្នុងចំណុច ឃ មាត្រា ៥១ នៃ ច.ប.ត.រ និងចំណុច ៦.៤.២០ ៦.៤.២១ និង ៦.៤.២២ នៃ ប.ន.ប.ច (ករណីចុះឈ្មោះបោះឆ្នោត) ឬ
- ចាត់ឱ្យ ន.គ.ទ.ប កែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ (ករណីកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ)។

- **ករណីយល់ព្រមលើបណ្តឹងជំទាស់**

ចាត់ឱ្យ ន.គ.ទ.ប លុបឈ្មោះអ្នកដែលត្រូវបានគេប្តឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

## ផ្នែកទី ៦
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត

ផ្នែកទី៦ នេះ កំណត់អំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ប.ន.ប.ច និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ ឬ/និងជនដែលជាមន្ត្រីបោះឆ្នោត ដែលអាចនាំឱ្យមានការពិន័យ។

### I. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្ដឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយទៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ឬទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សានៅ កបឃ.ស ឬទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួល ទ.១២០៣ របស់ គ.ជ.ប ។ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ដូចមានចែងក្នុង**ចំណុច ១ (ទំព័រ ១)** ។

### ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស

#### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ កបឃ.ស

ក. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។ អ្នកប្ដឹងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជូនខ្លួនបាន។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

គ. បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះផ្ដិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃកើតហេតុ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុថា **"ពាក្យបណ្ដឹងនេះបានដាក់ក្រោយអំឡុងពេលកំណត់ ដូចមានចែងក្នុងប្រការ ៧.៦ នៃ ប.ន.ប.ច ដែលជាហេតុផ្ដាច់សិទ្ធិក្នុងការប្ដឹងមក កបឃ.ស ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"** ។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ១ (ទំព័រ ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិក កបឃ.ស ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាង

មិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត មេឃុំ ចៅសង្កាត់ ឬ ជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.៣** ពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់**) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬ តំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

## ១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស

ក. បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ កបឃ.ស ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើបណ្ដឹង។ ក្នុងករណី កបឃ.ស ពិនិត្យ និងយល់ឃើញថា៖

១. ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើ ច.ប.គ.រ ឬ ប.ន.ប.ច កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

២. កម្មវត្ថុ និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើ ច.ប.ត.រ កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ថា " **ពាក្យបណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថាករណីនេះ ឬទាំងនេះគឺជាបទល្មើសព្រហ្មទណ្ឌ ពុំមែនជាសមត្ថកិច្ចរបស់ កបឃ.ស** "។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៣. ពាក្យបណ្តឹងដែលប្តឹងពីអញ្ញាតជន កបឃ.ស ត្រូវទទួលយកមកពិនិត្យ និងស្រាវជ្រាវរកអត្តសញ្ញាណរបស់អញ្ញាតជននោះ។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណជនប្រព្រឹត្តល្មើសមិនឃើញ កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងទៅដើមបណ្តឹងវិញអំពីករណីនេះ។

៤. ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ កបឃ.ស ត្រូវបង្កើតក្រុមគ្រូតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោម៖
- មេឃុំ ឬចៅសង្កាត់ ឬតំណាងជាប្រធានក្រុម
- សមាជិក កបឃ.ស ១ (មួយ) នាក់ ជាសមាជិក
- សមាជិក កបឃ.ស ១ (មួយ) នាក់ ជាលេខាធិការ។

ខ. ក្រុមគ្រូតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងបណ្តឹង។ ប្រធានក្រុមគ្រូតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹងអមដំណើរជាមួយបើមានការយល់ព្រមពីអ្នកប្តឹង។

គ. បន្ទាប់ពីក្រុមគ្រូតពិនិត្យស៊ើបអង្កេតចប់ហើយ លទ្ធផលបង្ហាញថាជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើ ច.ប.ត.រ និង ប.ន.ប.ច កបឃ.ស ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិត

រដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។

ឃ. ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើ ច.ប.ត.រ និង ប.ន.ប.ច **កបឃ.ស ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ កបឃ.ស ។**

ង. កបឃ.ស ត្រូវធ្វើកំណត់ហេតុនៃការផ្សះផ្សាដោយឱ្យគូភាគី ឬតំណាងផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ។

ច. ក្នុងការផ្សះផ្សា ប្រសិនបើភាគីទំនាស់ ៖

ច.១ **ព្រមព្រៀងគ្នា** កបឃ.ស ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ។

ច.២ **មិនព្រមព្រៀងគ្នា** កបឃ.ស ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ទោះបីភាគីណាមួយមិនព្រមផ្តិតមេដៃក៏ដោយ។ **កបឃ.ស ត្រូវប្រាប់ភាគីទាំងអស់ថា ភាគីណាមួយមិនសុខចិត្តនឹងលទ្ធផលនៃការផ្សះផ្សា អាចដាក់ពាក្យបណ្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សារួច។**

ឆ. កបឃ.ស ត្រូវបើកការប្រជុំផ្សះផ្សាចំពោះរាល់ពាក្យបណ្តឹងគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ប៉ុន្តែមិនមានអំណាចបើកអង្គប្រជុំសម្រេច និងចេញ ទ.១២០៣ ឡើយ។

ជ. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ កបឃ.ស ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូក២ ផ្នែកទី ១ នៃសៀវភៅណែនាំ នេះ **(ទំព័រ ៣៨)**។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងការផ្សះផ្សានៅ កបឃ.ស អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃ កបឃ.ស ផ្សះផ្សារួច។ អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។

**ខ.** នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនដូចក្នុង**ចំណុច ១ (ទំព័រ ១)** និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា។

**គ.** បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុសាកសួរនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ។

**ឃ.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុ ហើយឃើញថា៖

**ឃ.១** ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សានៅ កបឃ.ស គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

**ឃ.២** ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត

ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះ ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ង. ពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សានៅ កបឃ.ស មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់**) មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

ក. បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា៖

ក.១ ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើ ច.ប.ត.រ ឬ ប.ន.ប.ច គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពាន ច.ប.ត.រ

គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយនៅកបយ.ស គ.ជ.ប ត្រូវពិនិត្យសម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ១ (មួយ) ច្បាប់។

**ក.៤** ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ មានព័ត៌មានចាំបាច់ដូច **ចំណុច ១ (ទំព័រ ១)** គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

**ខ.** គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

**គ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកបណ្តឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្តឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹង ដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅអ្នកប្តឹង ដើម្បីជូនជ្រាបថាពាក្យបណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ. បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រក ឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹង គ.ជ.ប ត្រូវ **បើកសវនាការដោះស្រាយបណ្តឹងតាមពេលវេលាសមស្របជាបន្ទាន់**។

ង. គ.ជ.ប ត្រូវបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើបណ្តឹង ដោយធ្វើកំណត់ហេតុសវនាការ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ច. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី ២ ផ្នែកទី ១ នៃសៀវភៅណែនាំនេះ (**ទំព័រ ៣៩**)។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួល ទ.១២០៣ របស់ គ.ជ.ប ។

ខ. នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ៣.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការជាសាធារណៈដើម្បីពិនិត្យ និងសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

ខ. នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

គ. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ

គំនូសបំព្រួញទី៤

I. ការប្តឹងពីជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ



## II. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គ្រប់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ប.ច និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្ដឹង ក.ច.ប ឬ កបឃ.ស ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព ក.ច.ប ដំបូងត្រូវប្ដឹងទៅ កបឃ.ស តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ ២៥ ដល់ ៣៣)**។

**ខ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព កបឃ.ស ឬមន្ត្រីបោះឆ្នោត ត្រូវប្ដឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ ៣០ ដល់ ៣៣)**។

**គ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្ដឹងទៅរដ្ឋសភាដោយអនុលោមតាម ច.គ.ជ.ប ។

ពាក្យបណ្ដឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្ដឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយពាក្យបណ្ដឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្ដឹងរួចហើយ ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក្នុងករណីដែលរកឃើញថា៖**

- សមាជិក ឬមន្ត្រីនោះពិតជាបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ និង ប.ន.ប.ច ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មស្របតាម ច.ប.ត.រ ។
- សមាជិក ឬមន្ត្រីនោះបានគោរពតាម ច.ប.ត.រ និង ប.ន.ប.ច ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្ដឹងនោះ ហើយពាក្យបណ្ដឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

## គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គំនូសបំព្រួញទី៥

**II. ការប្តឹងពីជនដែលជាមន្ត្រីបោះឆ្នោត**






## ផ្នែកទី ៧
## នីតិវិធីអនុវត្តសេចក្តីសម្រេចស្ថាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់

ការអនុវត្តសេចក្តីសម្រេចស្ថាពរដាក់ទណ្ឌកម្មពិន័យជាប្រាក់ទៅលើជនល្មើស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ក. នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ជាអ្នកទទួលខុសត្រូវរៀបចំសំណុំឯកសារអនុវត្តសេចក្តីសម្រេចស្ថាពរ និងលើកសំណើតាមរយៈអគ្គលេខាធិការដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

ខ. តាមរយៈការសម្រេចឱ្យអនុវត្តសេចក្តីសម្រេចស្ថាពរ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចាត់វិធានការជូនដំណឹងទៅជនដែលត្រូវពិន័យឱ្យចូលខ្លួនមកអនុវត្តសេចក្តីសម្រេចដាក់ទណ្ឌកម្មពិន័យជាប្រាក់នោះដោយស្ម័គ្រចិត្ត ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីបង្គាប់។

គ. បើដល់ពេលកំណត់ ជនដែលត្រូវពិន័យមិនព្រមបង់ប្រាក់ពិន័យតាមសេចក្តីជូនដំណឹងទេនោះ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរៀបចំរបាយការណ៍ និងលើកសំណើតាមរយៈអគ្គលេខាធិការដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

ឃ. ក្នុងករណីដែល គ.ជ.ប យល់ឃើញថាគ្មានស្ថានភាពណាមួយដែល គ.ជ.ប ត្រូវពន្យារពេល ឬបន្ធូរបន្ថយ ឬលើកលែងទណ្ឌកម្មពិន័យជាប្រាក់ ឬរំលត់ការដាក់ទណ្ឌកម្មទេនោះ គ.ជ.ប អាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.ប ទារប្រាក់ពីជនដែលត្រូវពិន័យជូន គ.ជ.ប។

ង. ប្រាក់ពិន័យដែលទទួលបាន ត្រូវដាក់ចូលជាថវិកាជាតិ។

## ជំពូកទី ២
## សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង

### ផ្នែកទី ១
### សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

កបឃ.ស គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត។ កបឃ.ស បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច និង គ.ជ.ប ពិនិត្យសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹងដូចបានចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត។

ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### ១. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ កបឃ.ស ឬ គ.ជ.ប ។

#### ១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស

ប្រធាន និងសមាជិក កបឃ.ស ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា **ក្រុមប្រឹក្សាប្រជុំផ្សះផ្សា** ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេចហៅថា **ក្រុមប្រឹក្សាប្រជុំសម្រេច** ។ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស រួមមាន៖

- មេឃុំ ចៅសង្កាត់ ឬតំណាងជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច
- សមាជិក កបឃ.ស ជាសមាជិក
- សមាជិក កបឃ.ស ឬមន្ត្រីដែលបានចាត់តាំងដោយ កបឃ.ស ជាលេខាធិការ

លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទបញ្ជាផ្ទៃក្នុងរបស់ កបឃ.ស ។

### ១.២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្តឹង ហៅថា **ក្រុមប្រឹក្សាជំនុំជម្រះ**។

សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ជាគណៈលេខាធិការ។

លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ៥០ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវមានសំឡេងអនុបវាទឡើយ។

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

## ២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

### ២.១ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស

ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។ ដោយឡែកការប្រជុំសម្រេច អាចកោះហៅសាក្សីបាន។

ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច អាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយ

បំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី ៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង។

## ២.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះអាចបញ្ចូលរឿងក្តីក្នុងករណីដែលមានបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរហើយ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅបន្តប្រព្រឹត្តល្មើសទៀត ហើយបើមានបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត។

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

គ.ជ.ប មានសិទ្ធិធ្វើការស៊ើបអង្កេតលើករណីមាន ឬគ្មានបណ្តឹងក្នុងគោលបំណងឱ្យមានការគោរព ច.ប.ត.រ និង ប.ន.ប.ច និងដើម្បីឱ្យការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ នេះ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ក្នុងពេលសវនាការ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី ៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង។

# ផ្នែកទី ២

# សិទ្ធិ និងភារកិច្ចរបស់គូភាគី ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី

## ១. សិទ្ធិ និងភារកិច្ចរបស់គូភាគី

ក្នុងករណីគូភាគីមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬអ្នកការពារក្ដី ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងបណ្ដឹងឱ្យចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជនុំជម្រះមុនពេលបើកការប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិតែមិនតម្រូវឱ្យមានសាក្សីទេ។

គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ដោយមានចុះហត្ថលេខា ឬផ្ដិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ (តំណាងត្រូវតែជានីតិជន[៣])។

លិខិតប្រគល់សិទ្ធិនេះត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការយ៉ាងតិច ២ (ពីរ) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការ។

ដើមបណ្ដឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

គូភាគីមានសិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ត.រ និង ប.ន.ប.ច ។

---

[៣] ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ

## ២. សិទ្ធិ និងភារកិច្ចរបស់ដើមបណ្ដឹង

ដើមបណ្ដឹងអាចដកពាក្យបណ្ដឹងទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ កបឃ.ស បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។

ការដកពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ កបឃ.ស ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ កបឃ.ស ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្ដឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្ដឹងចោលដោយចេញ ទ.១២០៣។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្ដឹងដកពាក្យបណ្ដឹង ហើយពាក្យបណ្ដឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

ដើមបណ្ដឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិផងដែរ។ ចុងចម្លើយអាចបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្ដីរបស់ខ្លួន។

ដើមបណ្ដឹង ឬ/និងជនរងគ្រោះមានវិសមិតភាព[៤] រវាងឋានៈជាដើមបណ្ដឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី។ ដើមបណ្ដឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្ដល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

## ៣. សិទ្ធិ និងភារកិច្ចរបស់ចុងចម្លើយ

ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងបណ្ដឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលទទួលសិទ្ធិផងដែរ។ ចុងចម្លើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្ដីរបស់ខ្លួន។

---

[៤] ភាពដែលមិនអាចមាន ឬប្រកបកិច្ចការចូលគ្នាបាន

ចុងចម្លើយអាចបង្ហាញភស្តុតាង ជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយពីភស្តុតាងដែលមានដែរ។ ចុងចម្លើយអាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹងអំពីភស្តុតាងដែលគេមាន។

## ៤. សិទ្ធិ និងភារកិច្ចរបស់មេធាវី ឬតំណាង

មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

ដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់ភាគីអាចស្នើឱ្យ គបឃ.ស ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការថតចម្លងត្រូវធ្វើដោយមន្ត្រី គបឃ.ស ឬមន្ត្រីរាជការ គ.ជ.ប ដែលបានចាត់តាំង។

## ៥. សិទ្ធិ និងភារកិច្ចរបស់សាក្សី

សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវចំពោះមុខច្បាប់អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (**ខ្លឹមសារសម្បថមានក្នុងឧបសម្ព័ន្ធទី ៤ ស្តីពីនីតិវិធី និងខ្លឹមសារនៃសម្បថ**)។

សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នារង់ចាំការអញ្ជើញឱ្យចូលមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។ ហើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ។

សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់ជំនុំជម្រះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

## ផ្នែកទី ៣
## នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង (មានចែងក្នុងឧបសម្ព័ន្ធទី៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង)។

### ១. ប្រភេទសវនាការ

ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។

**សវនាការសង្ខេប** ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

**សវនាការតទល់** ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ។

**សវនាការសួរដេញដោល** ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គឺភាសាខ្មែរ។

ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

## ៣. ពេលវេលាដោះស្រាយពាក្យបណ្ដឹង

អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងរសៀល ចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី។ ក្នុងករណីចាំបាច់ អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្ដែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។

ក្នុងករណីដែលថ្ងៃកំណត់ដោះស្រាយបណ្ដឹង និងសម្រេចលើបណ្ដឹងចំថ្ងៃបុណ្យជាផ្លូវការ អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការត្រូវលើកទៅថ្ងៃបន្ទាប់។

ក្នុងកម្មវិធីមួយពេលនៃការបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការលើពាក្យបណ្ដឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬជំនុំជម្រះច្រើនករណីនៃបណ្ដឹងបាន។

## ៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬបើកសវនាការ

### ៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេចនៅ កបឃ.ស

កបឃ.ស ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេចនៅថ្នាក់របស់ខ្លួន ទៅតាមករណីនៃបណ្ដឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ត.រ និង ប.ន.ប.ច ។

កបឃ.ស ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។

### ៤.២ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្ដឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃបណ្ដឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ត.រ និង ប.ន.ប.ច ។

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវជានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលា យ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកសវនាការ។

## ៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ

លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការមានភារកិច្ចដូចខាងក្រោម៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅធ្វើសម្បថ (**ករណីប្រជុំសម្រេច ឬសវនាការ**)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរ នៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការដែលត្រូវស្រង់វត្តមានសាក្សី។
- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោយដៃ ឬដោយកុំព្យូទ័រ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ មិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខាលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងភាគីពាក់ព័ន្ធ ។
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធ តាមការបង្គាប់ពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

- រៀបចំ ទ.១២០៣ រួចចុះហត្ថលេខា រួចដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ។
- អញ្ជើញភាគីផ្ដិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្ដិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ។

## ៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

នៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្ដាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្ដាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។

ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ៖

ទី១. ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ទី២. ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ

ទី៣. បង្គាប់លេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្ដឹង ចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ)។

មុននឹងចាប់ផ្ដើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្ដឹងថា **តើលោក ឬលោកស្រីនៅតែបន្តប្ដឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្ដឹង ឬមានការកែប្រែឬទេ?** ប្រសិនបើ៖

- ដើមបណ្ដឹងឆ្លើយថាខ្លួនដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់ឱ្យលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬ កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្ដឹងផ្ដិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សា អាចផ្សះផ្សារឿងក្ដីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តទៅប្រជុំសម្រេច ឬជំនុំជម្រះរឿងក្ដីផ្សេងទៀត (ប្រសិនបើមាន)។
- ដើមបណ្ដឹងនៅតែបន្តប្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្ដើមដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។

ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរដេញដោលទៅដើមបណ្ដឹងមុន រួចសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្ដឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្ដឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

ប្រសិនបើមានមេធាវីការពារក្ដី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្ដល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្ដី សួរភាគី និងធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយមុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្ដឹងសុំដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬការសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្ដឹងដកពាក្យបណ្ដឹងពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយរួចហើយ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ ។

ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

## ៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេនោះ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច។

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតជូនដំណឹងហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកបណ្តឹងចោល ដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

ប្រសិនបើភាគីដើមបណ្តឹងស្លាប់ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវលុបបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការបញ្ជូន ទ.១២០៣ ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការ

គណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយក ទ.១២០៣ នោះលេខាធិការអង្គប្រជុំសម្រេច ឬមន្ត្រី គ.ជ.ប ត្រូវចារលើ ទ.១២០៣ នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា **"អ្នកប្តឹង ឬតំណាង ឬអ្នកត្រូវគេប្តឹង ឬតំណាងមិនព្រមទទួល ទ.១២០៣"** ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយ ដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួលយក ទ.១២០៣ រួចបិទ ទ.១២០៣ នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនៃពាក្យបណ្តឹង ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួល ទ.១២០៣ រួចហើយ។

## ៨. មធ្យោបាយបង្ហាញភស្តុតាង

មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការនេះ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរព ច.ប.ត.រ និង ប.ន.ប.ច ។

ជនណាបានប្រព្រឹត្តការក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន។

## ៩. ការប្រើប្រាស់ និងបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣)

ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ កបឃ.ស ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ហើយចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច។ ការបំពេញ ទ.១២០៣ នៅ កបឃ.ស ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងជំទាស់ ដើម្បី ៖

- ជូន ឬផ្ញើជូនសាមីអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ តាមរយៈ លធ.ខប ពាក់ព័ន្ធ
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់បណ្តឹងជំទាស់ដើម្បីៈ

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន កបយ.ស ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច ។ ទ.១២០៣ ត្រូវប្រគល់ជូនភាគីវិវាទភ្លាមៗបន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួល ទ.១២០៣ នេះត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលផ្ទាល់ក្នុងករណីៈ

- ភាគីវិវាទណាមួយបដិសេធមិនព្រមទទួលយក ទ.១២០៣ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់។
- ក្នុងករណីភាគីវិវាទជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវត្រូវបញ្ជូន ទ.១២០៣ ដោយមានដីកាអម ទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីកាអមត្រូវចាត់ទុកជាកាលបរិច្ឆេទទទួល ទ.១២០៣ ។

## ១០. ទម្រង់ផ្សេងៗសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ

កបឃ.ស និង គ.ជ.ប មានទម្រង់ផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការមានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ និងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ និងសេចក្ដីសម្រេចរបស់ គ.ជ.ប ។

លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវបំពេញតាមចំនួនជាក់ស្ដែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ រួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងទុកជាឯកសារ ១ (មួយ) ច្បាប់។

កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងបណ្ដឹង និងលទ្ធផលនៃការផ្សះផ្សា។

កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការអង្គសវនាការចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងបណ្ដឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

សេចក្ដីសម្រេចរបស់ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្ដឹង លិខិតប្រគល់សិទ្ធិ ឬ/និង កំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្ដីសម្រេចនេះអាចថតចម្លងផ្ដល់ជូនគូភាគីបាន ប្រសិនបើមានការស្នើសុំ។

# ឧបសម្ព័ន្ធទី ១
## ទម្រង់បែបបទពាក្យបណ្តឹង (ឧ.១២០២)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ពាក្យបណ្តឹង (ឧ.១២០២)

**I. សម្រាប់អ្នកប្តឹង**

១. អត្តសញ្ញាណអ្នកប្តឹង
- ឈ្មោះអ្នកប្តឹង : ................................ ភេទ ........ ថ្ងៃខែឆ្នាំកំណើត ................
- ទីលំនៅបច្ចុប្បន្ន : ផ្ទះលេខ ________ ផ្លូវ ______ ភូមិ ............ ឃុំ សង្កាត់ ............
  ក្រុង ស្រុក ខណ្ឌ ____________________ រាជធានី ខេត្ត ................
- តួនាទី/មុខងារ : ☐ប្រជាពលរដ្ឋ ☐ភ្នាក់ងារគណបក្សនយោបាយ ................
  ☐ផ្សេងៗ ................ ទូរស័ព្ទទាក់ទង ________________

២. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| រាជធានី ខេត្ត | | |
|---|---|---|
| លេខកូដ | | |

| ក្រុង ស្រុក ខណ្ឌ |
|---|
| |

| ឃុំ សង្កាត់ | | | |
|---|---|---|---|
| លេខកូដ | | | |

| លេខកូដការិយាល័យ | | | |
|---|---|---|---|
| | | | |

៣. កម្មវត្ថុនៃបណ្តឹង : ................................................................

................................................................

................................................................

................................................................

៤. មូលហេតុនៃការប្តឹង : ................................................................

................................................................

................................................................

................................................................

................................................................

................................................................

................................................................

................................................................

................................................................(ករណីត្រូវការបន្ថែមសូមសរសេរនៅខាងខ្នង)

៥. កាលបរិច្ឆេទ : ________/________/________

៦. ហត្ថលេខា ឬស្នាមមេដៃអ្នកប្តឹង (ប្រសិនបើអ្នកជាកំណាង ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរភ្ជាប់មកជាមួយ)

**II. សម្រាប់មន្ត្រីទទួលបន្ទុកការងារបោះឆ្នោត**

________________ ថ្ងៃទី ________ ខែ ________ ឆ្នាំ ________

| លេខពាក្យបណ្តឹង | កាលបរិច្ឆេទទទួលពាក្យបណ្តឹង | កាលបរិច្ឆេទប្រជុំសម្រេច ឬបើកសវនាការ |
|---|---|---|
| | ______/______/______ | |
| | ម៉ោង ________ ព្រឹក☐, រសៀល☐ | ______/______/______ |

**ហត្ថលេខា និងត្រា**

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញដោយអ្នកប្តឹងតវ៉ា ឬប្តឹងជំទាស់

# ឧបសម្ព័ន្ធទី ២

## ទម្រង់បែបបទសម្រាប់សេចក្តីសម្រេច (ឧ.១២០៣)

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

### សម្រង់សេចក្តីសម្រេច (ឧ.១២០៣)

១. លេខបណ្តឹង/សំណុំរឿង និងសេចក្តីសម្រេច

- បណ្តឹង/សំណុំរឿងលេខ__________ ចុះថ្ងៃទី______ ខែ________ ឆ្នាំ________ វេលាម៉ោង________
- សេចក្តីសម្រេចលេខ____________________ ចុះថ្ងៃទី__________ ខែ__________ ឆ្នាំ________

២. អត្តសញ្ញាណអ្នកប្តឹង

- ឈ្មោះអ្នកប្តឹង____________________ ភេទ__________ ថ្ងៃខែឆ្នាំកំណើត__________
- ទីលំនៅបច្ចុប្បន្នផ្ទះលេខ__________ ផ្លូវ________ ភូមិ__________ ឃុំ សង្កាត់__________
  ក្រុង ស្រុក ខណ្ឌ______________________________ រាជធានី ខេត្ត______________
- តួនាទី/មុខងារ________________________________________

៣. កម្មវត្ថុនៃបណ្តឹង________________________________________

________________________________________

________________________________________

៤. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| រាជធានី ខេត្ត | | |
|---|---|---|
| លេខកូដ | | |

| ក្រុង ស្រុក ខណ្ឌ |
|---|
| |

| ឃុំ សង្កាត់ | | | |
|---|---|---|---|
| លេខកូដ | | | |

| លេខកូដការិយាល័យ | | | |
|---|---|---|---|
| | | | |

### សម្រេច

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច**

**ហត្ថលេខា និងត្រា**

**បានស្រង់ត្រឹមត្រូវតាមច្បាប់ដើម**

__________ ថ្ងៃទី________ ខែ________ ឆ្នាំ________

**លេខាធិការសវនាការ ឬអង្គប្រជុំសម្រេច**

**ហត្ថលេខា**

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញដោយក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច

# ឧបសម្ព័ន្ធទី ៣
# បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង

ដើម្បីរក្សាសណ្ដាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការដូចជា៖
   - ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហោតរហូត ដោយគ្មានការអនុញ្ញាត
   - ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣. ហាមយកក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦. ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៧. ក្នុងករណីជនណាបង្កបញ្ហាអ្វីមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្ដេញជននោះ ចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវទទួលទោសតាមច្បាប់ជាធរមាន។

# ឧបសម្ព័ន្ធទី ៤
# នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូបបូជានៅចំពោះមុខវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវរត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិតតាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនាអស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិតព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿងសមដូចប្រាថ្នាកុំបីអាក់ខានឡើយ។

### ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ ទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

## ឧបសម្ព័ន្ធទី ៥
## សម្រង់មាត្រាពាក់ព័ន្ធនឹងទោសប្បញ្ញត្តិ ក្នុងពេលចុះឈ្មោះបោះឆ្នោត ដែលមានចែងក្នុងជំពូកទី១០ នៃ ច.ប.ត.រ

**មាត្រា ១៤០ .-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់អាចបោះឆ្នោតបាន។

**មាត្រា ១៤១ .-**

ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណពាក់ព័ន្ធនឹងការបោះឆ្នោត។

**មាត្រា ១៤២ .-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សា ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា ១៤៤.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ លើកលែងតែមានការអនុញ្ញាតដោយច្បាប់នេះ។

**មាត្រា ១៤៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និង

ក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត ដូចបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួន ចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បោះពុម្ព និងផ្សព្វផ្សាយដោយ
គ.ជ.ប

ឆ្នាំ ២០១៧